អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះអនុស្សរណៈនៃការយោគយល់ជាមួយ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(គ.ម.ក) លើកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាល និងការលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់ជូនសមាជិក-សមាជិកានៃ គ.ម.ក

អនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល និងលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់ជូនសមាជិក-សមាជិកានៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (គ.ម.ក) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ រវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) តំណាងដោយ**ឯកឧត្តម ក្រាញ់ តូនី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយ **ឯកឧត្តម លី ច័ន្ទតុលា** ប្រធាន គ.ម.ក។

អនុស្សរណៈនៃការយោគយល់នេះមានគោលបំណងបង្កើនកិច្ចសហការលើការងារចែករំលែក ចំណេះដឹង បទពិសោធន៍ច្បាប់ ការស្រាវជ្រាវ និងការអនុវត្តជាក់ស្តែងផ្សេងៗនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជូនដល់សមាជិកសមាជិកានៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈកម្មវិធីរួមគ្នា នៃកម្មវិធីបណ្តុះបណ្តាលនានា ដែលមានជាអាទិ៍ សិក្ខាសាលា ការបង្កើតកម្មវិធីសិក្សាសម្រាប់សិស្សមេធាវី ទស្សនកិច្ចសិក្សា ការធ្វើសវនាការត្រាប់ នៅស្ថាប័ន អ.វ.ត.ក. និងការងារផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងចំណេះដឹងច្បាប់។

ឯកឧត្តម **ក្រាញ់ តូនី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. បានមានប្រសាសន៍ថា៖ អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខានេះ គឺជាការចូលរួមអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក. ដែលរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ បានឯកភាពគ្នាលើ «កិច្ចព្រមព្រៀងបន្ថែមស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ» សម្រាប់រយៈពេល៣ឆ្នាំបន្ថែម គឺពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ដែលរួមមាន៖ (ក) ការងារគតិយុត្តមួយចំនួនរួមទាំងការគ្រប់គ្រង និងការផ្សព្វផ្សាយបណ្ណសារស្តីពីសំណុំរឿងរបស់ អ.វ.ត.ក. ឱ្យបានទូលំទូលាយ (ខ) ការអប់រំ និងការផ្សព្វផ្សាយស្តីពីសមិទ្ធផលនិងកេរដំណែលរបស់

អ.វ.ត.ក. និងការពិនិត្យតាមដានការអនុវត្តសំណង ដែលមានលក្ខណៈផ្លូវចិត្ត និងសមូហភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី»។ ឯកឧត្តមក៏បានបញ្ជាក់បន្ថែមផងដែរថា អ.វ.ត.ក. គឺជាមណ្ឌលឯកសារមួយដ៏សំខាន់សម្រាប់អ្នកស្រាវជ្រាវជាពិសេសលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

ឯកឧត្តម **លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកការចុះអនុស្សរណៈនេះថាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការជាមួយសាលាក្តីខ្មែរក្រហមលើការបណ្តុះបណ្តាល ការលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់ និងជាពិសេសការសិក្សាស្រាវជ្រាវ។ ឯកឧត្តមបានបញ្ជាក់ថា កិច្ចសហការនេះគឺជាឱកាសមួយសម្រាប់មេធាវីទាំងអស់ក្នុងការទទួលបាននូវចំណេះដឹង បទពិសោធន៍ និងការអនុវត្តជាក់ស្តែងផ្នែកច្បាប់ បន្ថែមទៀត សំដៅពង្រឹង និងបង្កើនចំណេះដឹងរបស់ពួកគាត់ ហើយជាងនេះទៅទៀត ឯកឧត្តមបន្ថែមថាគណៈមេធាវីនឹងជួយផ្សព្វផ្សាយអំពីសមិទ្ធផលរបស់ អ.វ.ត.ក. ដល់សាធារណៈជន ផងដែរ។

សូមបញ្ជាក់ថា ការចុះអនុស្សរណៈនៃការយោគយល់នេះ ជាផ្នែកមួយនៃការចែករំលែកនូវបទពិសោធន៍ និងផ្តល់ឯកសារសម្រាប់ការស្រាវជ្រាវដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវ ក្នុងគោលដៅចូលរួមបណ្តុះបណ្តាលធនធានមនុស្ស និងផ្សព្វផ្សាយនូវសមទ្ធផលផ្នែកច្បាប់ដ៏មានតម្លៃរបស់អង្គជំនុំជម្រះសម្រាប់មនុស្សជាតិទាំងមូលដើម្បីជាប្រយោជន៍ដល់ ការលើកកំពស់វិស័យយុត្តិធម៌អន្តរជាតិ៕